# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែមករា-កុម្ភៈ ឆ្នាំ២០១៨ / January-February 2018**

**មាតិកា**


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៤** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៤ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៥ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៦ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៧ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍/Tourism | ៩ |
| ១.៧. វិស័យសំណង់/Construction | ១០ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** | **១០** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១០ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១០ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១១ |
| **៣. ឧបសម្ព័ន្ធ** | **១២** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែមករា ឆ្នាំ២០១៨ បានកើនឡើងក្នុងអត្រា **0,១%** ធៀបនឹងខែមុន និងកើនឡើង **២,0%** បើធៀបនឹង១២ខែមុន។ ក្នុងខែមករានេះ សន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹងបានកើនឡើងក្នុងអត្រាត្រឹមតែ ១,៥% ទាបជាងកំណើនជាមធ្យមក្នុងរយៈពេល ២ឆ្នាំចុងក្រោយ (២០១៦-២០១៧) ដែលមានអត្រា ៤,៥% ដែលការថមថយកំណើននេះ មួយផ្នែកគឺបណ្តាលមកពីការថមថយកំណើននៃ ថ្លៃសាច់ស្រស់, ត្រីស្រស់, បន្លែ និងផ្លែឈើជាដើម។

**២. ឥណទាន÷** គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ៦៩.៣៥៧ប៊ីលានរៀល បានកើនឡើង ១,៤%ធៀបនឹងខែមុន និងកើនឡើង ១៩,១%ធៀបនឹង១ឆ្នាំមុន។ នៅក្នុងខែធ្នូ ឆ្នាំ២០១៧ ធនាគារជាតិបានដាក់ឱ្យអនុវត្តប្រកាសស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមិន ក្នុងគោលបំណងពង្រឹងបន្ថែមទៀតអំពីការវាស់វែង ការធ្វើសំវិធានធន និងការរាយការណ៍ចំពោះហ្វាស៊ីលីធីដែលមានអ៊ីមភែរមិន របស់គ្រឹះស្ថានក្រោមឱវាទ។

**អត្រាការប្រាក់÷** ÷ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ អត្រាការប្រាក់ធនាគារពាណិជ្ជចំពោះកម្ចីជាប្រាក់រៀល និងដុល្លារស្មើនឹង ១២,២៤% និង ១១,៦៥% បានថយចុះបន្តិចធៀបទៅនឹងចុងឆ្នាំ២០១៧កន្លងទៅ។ អត្រាការប្រាក់កម្ចីជារៀលនៅតែខ្ពស់ជាងប្រាក់ដុល្លារ ដែលមួយផ្នែកដោយសារលក្ខណៈកម្ចីប្រាក់រៀលភាគច្រើនជាប្រភេទកម្ចីខ្នាតតូច និងសម្រាប់អតិថិជនជាកសិករឬនៅទីជនបទ និងប្រតិបត្តិការជាប្រាក់រៀលមានទំហំតូច ដែលនាំឱ្យមានចំណាយប្រតិបត្តិការខ្ពស់ក្នុងន័យសេដ្ឋកិច្ចមាត្រដ្ឋាន។

**ការផ្គត់ផ្គង់រូបិយវត្ថុ÷** គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ រូបិយវត្ថុទូទៅ M2 បានកើនដល់ ៧៣.១៧៥ប៊ីលានរៀល បានកើនឡើង ១,៣% ធៀបនឹងខែមុន (កើនឡើង ២២,៨% ធៀបនឹង១ឆ្នាំមុន), ក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសមានចំនួន ៦០.៩៣៨ប៊ីលានរៀល បានកើនឡើង ១,៤% ធៀបនឹងខែមុន។

ក្នុងខែមីនា ឆ្នាំ២០១៨ តម្លៃជួញដូរលើទីផ្សារមូលបត្រកម្ពុជា (CSX) មានចំនួន ៣២២លានរៀល បានថយចុះ ៣៦%ធៀបទៅនឹងខែកុម្ភៈកន្លងទៅ ដែលមានតម្លៃជួញដូរ ៥០៤លានរៀល។

**៣.** ក្នុងឆ្នាំ២០១៧ ទំហំទឹកប្រាក់នៃការនាំចូលមានចំនួន ១៣.៦១៥លានដុល្លារ បានកើនឡើង ១១,២%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះការនាំចូលគ្រឿងយន្តកើនឡើង ១២,៧%, ទំនិញវាយនភ័ណ្ឌកើនឡើង ៥,៧% និងបរិក្ខារសំណង់កើនឡើង ១២,៨%។ រីឯទំហំទឹកប្រាក់នាំចេញមានចំនួន ១១.១៤២លានដុល្លារ បានកើនឡើង ៩,៤% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ក្នុងនោះការនាំចេញផលិតផលវាយនភ័ណ្ឌនិងស្បែកជើងកើនឡើង ៧,៧% និងការនាំចេញផលិតផលកៅស៊ូកើនឡើង ៥៣,៨%។

**៤.** នៅរយៈពេល ២ខែ ដើមឆ្នាំ២០១៨ នេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលសរុបដែលចំណូលទាំងអស់ជាប្រភេទចំណូលចរន្តបានចំនួន ២.៥៧៥,៦០ ប៊ីលានរៀល គឺស្មើនឹង ១៤,៦% ធៀបច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬបានកើនឡើង ៣,៣% បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ ក្នុងនោះ ចំណូលពន្ធប្រយោលបានកើនឡើង ៥,៩% ចំណូលពន្ធពីពាណិជ្ជកម្មក្រៅប្រទេស ១៥,៧% និងចំណូលមិនមែនសារពើពន្ធ ៦៣,៧%។

តាមទិន្នន័យបឋមពីរតនាគារជាតិ នៅរយៈពេល ២ខែ ដើមឆ្នាំ២០១៨នេះ ចំណាយសរុបនៅរដ្ឋបាលថ្នាក់ជាតិអនុវត្ត បានចំនួន ១.៩៨៣,២៩ ប៊ីលានរៀល គឺស្មើនឹង ៨,៧% ធៀបច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងនោះ ចំណាយចរន្តអនុវត្តបាន ចំនួន ១.៧៣២,៧០ ប៊ីលានរៀល គឺស្មើនឹង ១១,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ឬបានកើនឡើង ៣៤,២% ធៀបនឹង រយៈពេលដូចគ្នាឆ្នាំ២០១៧ ពោលគឺការអនុវត្តមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លង ទៅដោយសារកំណែទម្រង់លើនិតិវិធីចំណាយ និងអ្នកអនុវត្តកាន់តែយល់ជ្រួតជ្រាបពីនិតិវិធីនានា។

**៥.** រយៈពេល ២ខែដើមឆ្នាំ២០១៨នេះ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុម ប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន ១៨គម្រោង និងមានទុនវិនិយោគចំនួន ១៧៧លានដុល្លារអាមេរិក កើនឡើងប្រមាណ ៥១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ និងអាចបង្កើតការងារបានប្រមាណ ១៥ពាន់កន្លែង។

**៦.** ខែមករាដើមឆ្នាំ២០១៨ ចំនួនមកដល់នៃភ្ញៀវទេសចរអន្តរជាតិសរុបមានប្រមាណ ៥៩៦ពាន់នាក់ បានកើន ឡើង ១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ ភ្ញៀវទេសចរភាគច្រើនគឺជនជាតិចិន, វៀតណាម, កូរ៉េ, ឡាវ, ថៃ និង សហរដ្ឋអាមេរិច។

**៧.** រយៈពេល ២ខែដើមឆ្នាំ២០១៨ សំណើសុំសាងសង់សរុបមាន ៥៨៦គម្រោង មានការកើនឡើងគួរឱ្យកត់ សម្គាល់ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (កើនឡើង ៤៥គម្រោង) ដែលភាគច្រើនគឺកើនឡើងលើប្រភេទសំណង់លំនៅដ្ឋាន និងពាណិជ្ជកម្ម។

**៨.** ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ប្រេងឆៅ (Brent) ថ្លៃ ៦៥,៧៨ដុល្លារ/បារ៉ែល ធ្លាក់ថ្លៃ ៣,២៧ដុល្លារ/បារ៉ែល, ប្រេងឆៅ (Dubai) ថ្លៃ ៦៣,២ដុល្លារ/បារ៉ែល ធ្លាក់ថ្លៃ ២,៦ដុល្លារ/បារ៉ែល និងប្រេងឆៅ (WTI) ថ្លៃ ៦១,៤៤ដុល្លារ/បារ៉ែល ធ្លាក់ថ្លៃ ៣,២៩ដុល្លារ/បារ៉ែល ធៀបនឹងខែមុន។

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ **អង្ករនាំចេញរបស់កម្ពុជា (ខ្ទេច ៥%)** ថ្លៃ ៤៨០ដុល្លារ/តោន ធ្លាក់ចុះ ៥ដុល្លារ/តោន ធៀបនឹងខែមុន។ ឆ្លើយតបនឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលចិន ក្នុងការលើកទឹកចិត្តឱ្យមានការ ពង្រីកវិស័យពាណិជ្ជកម្មឱ្យកាន់តែធំថែមទៀតនោះ កម្ពុជាអាចនាំចេញអង្ករទៅប្រទេសចិនប្រមាណ ៣០០ពាន់តោនក្នុងឆ្នាំ ២០១៨នេះ យោងតាម Freshnewsasia.com។ **អង្ករនាំចេញរបស់ថៃ (ខ្ទេច ៥%)** ថ្លៃ ៤១៤ដុល្លារ/តោន ធ្លាក់ចុះ ៤៧ ដុល្លារ/តោន ធៀបខែមុន ដោយសារភាពប្រកួតប្រជែងនៃការនាំចេញអង្ករមានការកើនឡើងខ្លាំងទាំងទីផ្សារតំបន់ និងអន្តរជាតិ។ ទោះបីជា អង្ករនាំចេញរបស់កម្ពុជា និងថៃ (ខ្ទេច ៥%) បានធ្លាក់ថ្លៃក៏ពិតមែន ប៉ុន្តែ**អង្ករនាំចេញរបស់វៀតណាម** (ខ្ទេច ៥%) ថ្លៃ ៤៤០ ដុល្លារ/តោន បានកើន ២៥ ដុល្លារ/តោន ធៀបខែមុន។ សូមគូសបញ្ជាក់ថា ប្រទេសវៀតណាមបានចុះ អនុស្សរណៈកិច្ចព្រមព្រៀងពាណិជ្ជកម្មនាំចេញអង្ករទៅប្រទេសបង់ក្លាដេស ក្នុងបរិមាណ ១លានតោន/ឆ្នាំ រហូតដល់ឆ្នាំ ២០២២។

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ កៅស៊ូឆៅស្តង់ដារ TSR20 លើទីផ្សារអាស៊ី ថ្លៃ ១.៤៩០ដុល្លារ/តោន បានធ្លាក់ចុះ ១០ ដុល្លារ/តោន ធៀបខែមុន។ ការធ្លាក់ចុះនេះ ដោយសារការផ្គត់ផ្គង់កៅស៊ូធម្មជាតិលើសពីតម្រូវលើទីផ្សារពិភពលោក ពោល គឺផលិតកម្មកៅស៊ូឆ្នាំ២០១៧ សម្រេចបាន ១២,៩០ពាន់លានតោន ខណៈតម្រូវការមាន ១២,៨២ពាន់លានតោន។

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)

**Construction Approval in Nationwide (0000m2)**




Source: Min. LMUC

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា រូបិយវត្ថុ និងទុនបំរុងបរទេស (Inflation, M2 and Foreign Reserve)


















# អត្រាប្តូរប្រាក់ (Exchange Rate)

### Exchange rate R/100Đ and R/B




Source: IMF

### Exchang Rate Mal-Ringgit/$ and Phi-Peso/$




Source: IMF

### CPI and Exchange rate R/$




Source: IMF

### Exchange rate EU Euro/US$ and Pound/US$




Source: IMF

### Exchange rate Aus-$ and HK-$




Source: IMF

### Exchange rate Sing-$ and Yen-$




Source: IMF

# ធនាគារនិងទីផ្សារមូលបត្រ (Banking and Securities Market)




Source: NBC




Source: NBC




Source: NBC




Source: NBC




Source: NBC




*Source: Cambodia Securities Exchange*

# ការអនុវត្តថវិកា (Budget)

**ចំណាយបៀវត្ស និង មិនមែនបៀវត្ស ឆ្នាំ ២០១៧-២០១៨**




Source: MEF

**ចំណាយការពារសន្តិសុខ និង រដ្ឋបាលស៊ីវិលឆ្នាំ ២០១៧-២០១៨**




**ចំណូលក្នុងប្រទេស និង ពន្ធលើពាណិជ្ជកម្ម ឆ្នាំ ២០១៧-២០១៨**




**ចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ឆ្នាំ២០១៧-២០១៨**




**ចំណាយចរន្ត និង វិនិយោគឆ្នាំ ២០១៧-២០១៨**




**ការដកសាច់ប្រាក់កម្ចីទ្វេភាគី និងពហុភាគី ឆ្នាំ ២០១៧-២០១៨**



# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)


















# វិស័យពាណិជ្ជកម្ម (Trades)




Source: Customs and Excise Department




Source: Customs and Excise Department




Source: National Bank of Cambodia, NBC, and Customs




Souce: Customs and Excise Department, MEF
(including foreign currency exports )




Souce: Customs and Excise Department, MEF




Souce: Customs and Excise Department, MEF

<u>**កំណត់សម្គាល់**</u>

កៅស៊ូ÷

- កៅស៊ូTSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូSIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេ គឺកៅស៊ូស្តង់ដារ(កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូTSR20ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូលជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាមនិងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets)បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទRSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុសម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់រថយន្ត និងដែលជាធាតុផ្សំលើស 50%នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅBrent, WTI និងDubai ជាប្រភេទប្រេងឆៅធុនស្រាល(Light Crude Oil)ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ ប្រភេទប្រេងBrentច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិកWTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីតDubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

**រៀបចំដោយ**

**នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច**

**អគ្គនាយកដ្ឋានគោលនយោបាយ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*